# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ :** ២៧...សសរ...

# សេចក្ដីសម្រេច
## ស្ដីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ៩៦ប្រក.បល ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងមន្ត្រីរាជការ
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.-**

ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ចំនួន ០៤រូប ដូចមានរាយនាមខាងក្រោម៖

១. លោក **គី គានសេន** ជាប្រធាននាយកដ្ឋានស្ដីទី នៃនាយកដ្ឋានរៀបចំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងកិច្ចប្រជុំផ្សេងទៀត នៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការទូទៅ

២. កញ្ញា **គីម ម៉ារីយ៉ាន** ជាប្រធាននាយកដ្ឋានស្ដីទី នៃនាយកដ្ឋានស្រាវជ្រាវនិងរៀបចំឯកសារគាំទ្រកិច្ចប្រជុំ នៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការទូទៅ

៣. លោក **ប៉ា ប៉ុណ្ណារ៉ាដា** ជាប្រធាននាយកដ្ឋានស្ដីទី នៃនាយកដ្ឋានអាស៊ាន នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៤. លោក **ម៉ុម មុនី** ជាប្រធាននាយកដ្ឋានស្តីទី នៃនាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងបរិស្ថាន នៃអគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ២.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

**កន្លែងទទួល :**

- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងមុខងារសាធារណៈ*
- *ដូចប្រការ២*
- *ឯកសារ-កាលប្បវត្តិ*